# Gideon – the unwilling saviour

# គីឌាន អ្នកសង្គ្រោះដែលគ្មានឆន្ទៈ

Judges 6:1-17

ពួកចៅហ្វាយ ៦:១-១៧

បងប្អូន នៅពេលខ្ញុំបានអធិប្បាយលើកមុន នៅខែកុម្ភៈ យើងបានមើលក្នុងកណ្ឌចៅហ្វាយ គឺជាពេលវេលាដែលរាស្ត្ររបស់ព្រះអត់ចេះច្បាប់របស់ទ្រង់ អត់គោរពព្រះ គ្មានរបៀបរៀបរយ ហើយគ្មានអ្នកត្រួតត្រា។ ដូច្នេះអ្នកនិពន្ធបានប្រាប់ជាច្រើនដងថា នៅសម័យនោះពួកគេគ្មានស្តេច។

នៅសម័យបុរាណនោះ គឺប្រហែលជា៣០០ឆ្នាំ ដែលព្រះបានចាត់ចៅហ្វាយចំនួនដប់ពីរនាក់មកដល់ពួកគេ ដើម្បីដឹកនាំកុលសម្ព័ន្ធផ្សេងៗ នៅក្នុងអ៊ីស្រាអែល។ នៅពេលមុនខ្ញុំបានអធិប្បាយអំពីមនុស្សប្រុសម្នាក់ មានឈ្មោះថា អេហ៊ូដ ដែលជាបុរសប្រើតែដៃឆ្វេងប៉ុណ្ណោះ ប៉ុន្តែគាត់បានក្លាយជាអ្នកសង្គ្រោះរបស់ព្រះ ចេញពីអំណាចរបស់ពួកម៉ូអាប់ ដើម្បីអោយពួកអ៊ីស្រាអែលអាចរីករាយដោយសន្តិភាពក្នុងទឹកដីសន្យាអស់រយៈពេល៨០ឆ្នាំ។

ប្រហែលជាអ្នកបានចាំពីវង់មូល ដែលខ្ញុំបានបង្ហាញមុនហើយ។

វង់មូលនេះបានបង្ហាញអំពីការកើតមានឡើងដដែលៗ គឺ

- ពួកអ៊ីស្រាអែលធ្វើអំពើបាប
- គេបានទទួលការកាត់ទោសរបស់ព្រះ
- ពួកគេប្រែចិត្ត
- ព្រះបានចាត់អ្នកសង្គ្រោះ
- ពួកគេមានពេលវេលារីករាយដោយសន្តិភាពនិងភាពសំបូរសប្បាយ។

អត្ថបទដែលយើងបានអានថ្ងៃនេះ ចាប់ផ្តើមដោយពាក្យនេះ ៖

‹‹ជនជាតិអ៊ីស្រាអែលនាំគ្នាប្រព្រឹត្តអំពើអាក្រក់ ដែលមិនគាប់ព្រះហឫទ័យ**ព្រះអម្ចាស់**សាជាថ្មីទៀត ហេតុនេះហើយបានជាព្រះអង្គប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់ជនជាតិម៉ាឌានអស់រយៈពេលប្រាំពីរឆ្នាំ។›› (៦:១)

ជនជាតិម៉ាឌាន ៖

- ជាក្រុមសាសន៍ដទៃដែលបានមកមានច្រើនអនេកដូចកណ្តូប គឺទាំងមនុស្ស ទាំងសត្វអូដ្ឋ មានចំនួនច្រើនឥតគណនាចូលមកបំផ្លាញស្រុកអ៊ីស្រាអែល។
- ពួកគេទៅវាល់ឆ្នាំ អស់រយៈពេលប្រាំពីរឆ្នាំ
- ឥឡូវជីវិតនៅក្នុងទឹកដីសន្យាពិបាកមែនទែន ‹‹ដូច្នេះជនជាតិអ៊ីស្រាអែលបានយករអាងភ្នំ រូងភ្នំ និងចំណោតភ្នំធ្វើជាជំរក ដើម្បីគេចខ្លួនពីជនជាតិម៉ាឌាន។
- ដូច្នេះ ឥឡូវនេះពួកអ៊ីស្រាអែលត្រូវពួននៅក្នុងទឹកដីខ្លួន
- ពិតមែនហើយ ឥឡូវនេះពួកគេវេទនាខ្លាំងណាស់ បានជាពួកគេបាន ‹‹ស្រែកអង្វរ**ព្រះអម្ចាស់**អោយជួយសង្គ្រោះគេ។››

ដូច្នេះ ម្តងទៀត យើងបានឃើញថា ពួកអ៊ីស្រាអែលត្រូវជួបនឹងសេចក្តីវេទនាក្នុងពេលយូរណាស់ មុនពេលពួកគេបានស្រែកអង្វរចំពោះព្រះទៅទៀត ពីព្រោះពួកគេជាកូនចចេស។

បងប្អូន ប្រហែលជាយើងធ្វើដូចនេះ គឺនៅពេលជីវិតរបស់យើងមានភាពងាយស្រួល ឬសេចក្តីរីករាយ យើងបានភ្លេចពីព្រះ ប៉ុន្តែនៅពេលយើងមានជីវិតលំបាក ឬមានសេចក្តីវេទនា នោះទើបយើងបានចាប់ផ្តើមអង្វរចំពោះព្រះដែរ។

តើនៅពេលពួកអ៊ីស្រាអែលបានរងសេចក្តីវេទនា ហើយពួកគេបានស្រែកអង្វរដល់ព្រះ ពួកគេចង់បានអ្វី? ពួកគេចង់ដោះស្រាយបញ្ហាដែលគេមាន គឺពួកគេចង់បានអោយព្រះចាត់មេទាហាន អ្នកស្ទាត់ខាងចំបាំង វីរបុរស ដែលនឹងដឹកនាំពួកគេ ដើម្បីពួកគេនឹងឈ្នះលើសត្រូវរបស់ខ្លួន ហើយពួកគេនឹងទទួលបានសេរីភាពនិងឯករាជ្យនៅក្នុងទឹកដីសន្យា។ ប៉ុន្តែ តើព្រះបានចាត់អ្នកណា? ព្រះបានចាត់ព្យាការីម្នាក់ ហើយព្យាការីនោះបានបង្រៀនពីប្រវត្តិសាស្ត្ររបស់ជនជាតិនោះ គឺគាត់បានចាប់ផ្តើមដោយពាក្យថា ‹‹យើងបាននាំ

អ្នករាល់គ្នាចេញពីស្រុកអេស៊ីប...››  ហើយគាត់បានបញ្ចប់ដោយពាក្យ ‹‹តែអ្នករាល់គ្នាមិនបានស្តាប់យើងសោះ»។

នៅពេលពួកអ៊ីស្រាអែលបានទទួលព្រះបន្ទូលនោះ ប្រហែលជាគេបានគិតថា គេនឹងទទួលការកាត់ទោសពីព្រះ ប៉ុន្តែព្រះបានធ្វើអ្វី?ទ្រង់បានចាត់ទេវតារបស់ទ្រង់អោយមកដល់មនុស្សម្នាក់ គឺគីឌាន ដែលជាមនុស្សភ័យខ្លាចចំពោះសត្រូវ។ គីឌានមិនមែនជាទាហានមិនមែនជាវីរជន ប៉ុន្តែគាត់ជាមនុស្សខ្លាចនិងឥតប្រយោជន៍។  ទេវតាបានរកគីឌានឃើញ ដែលគាត់ ‹‹ កំពុងតែបោកបែនស្រូវ ក្នុងធុងសំរាប់គាបផ្លែទំពាំងបាយជូរ ដើម្បីកុំអោយជនជាតិម៉ាឌានឃើញ››។

តើទេវតាបានជួបនឹងគីឌានដោយរបៀបណា? គឺដោយពាក្យថា «វីរជនដ៏អង់អាចអើយ **ព្រះអម្ចាស់**គង់នៅជាមួយអ្នកហើយ!»។ (៦:១២)

ប្រហែលជាអ្នកគិតថា នៅពេលគីឌានបានទទួលព្រះបន្ទូលនោះ គាត់ទទួលបានការលើកទឹកចិត្ត ផ្ទុយទៅវិញសំរាប់គាត់ ព្រះបន្ទូលនោះបានបង្ហាញអោយគាត់មើលឃើញឧបសគ្គជាច្រើន (៦:១៣)។

លោកគេឌានឆ្លើយតបវិញថា «លោកម្ចាស់អើយ ប្រសិនបើ**ព្រះអម្ចាស់**គង់នៅជាមួយយើងមែន ហេតុអ្វីក៏ទុក្ខវេទនាទាំងនេះកើតមានដល់យើង? ឯណាទៅការអស្ចារ្យទាំងប៉ុន្មានដែលដូនតារបស់យើងតែងតែតំណាលប្រាប់ ទាំងបញ្ជាក់ថា **ព្រះអម្ចាស់**បាននាំយើងចេញពីស្រុកអេស៊ីបមកនោះ? ឥឡូវនេះ **ព្រះអម្ចាស់**បោះបង់ចោលយើងហើយ ព្រះអង្គបានប្រគល់យើងទៅក្នុងកណ្តាប់ដៃរបស់ជនជាតិម៉ាឌាន!»។

យើងអាចមើលឃើញថា គីឌាន**អត់ដឹង**អំពីមូលហេតុនៃស្ថានភាពរបស់ពួកអ៊ីស្រាអែលទេ គឺគាត់**អត់ដឹងអ្វី**សោះអំពីស្ថានភាពខាងវិញ្ញាណរបស់ពួកគេ គឺគាត់**អត់ដឹង**ពីកំហុសដ៏ធ្ងន់ធ្ងរនៃការថ្វាយបង្គំរូបព្រះ ដែលពួកគេបានប្រព្រឹត្តរហូតមកនៅក្នុងទឹកដីសន្យា។ ដូច្នេះយើងអាចឃើញថា គីឌានមិនយល់អំពីព្រះបន្ទូល ដែលគាត់បានទទួលពីព្យាការីនៅពេល

មុនទេ។

លើសពីនេះទៅទៀត គីឌានមានអាកប្បកិរិយាហែជំទាស់ ដូច្នេះគាត់បន្ទោសព្រះសំរាប់ស្ថានភាពលំបាករបស់ពួកអ៊ីស្រាអែល។ គាត់បានគិតថា ស្ថានភាពទាសភាពនៅស្រុកអេស៊ីព្ទល្អជាងស្ថានភាពឥឡូវនេះ ប៉ុន្តែពាក្យរបស់គាត់ស្រដៀងគ្នានឹងពាក្យរបស់ពួកអ៊ីស្រាអែលនៅក្នុងទីរហោស្ថានដែរ គឺនៅពេលពួកគេបដិសេធចូលទៅក្នុងទឹកដីសន្យា បានជាពួកគេជំនាន់នោះត្រូវស្លាប់ក្នុងទីរហោស្ថាន មុនពេលកូនចៅរបស់ពួកគេអាចចូលទឹកដីម្តងទៀត។

ប៉ុន្តែទេវតាមិនអស់សង្ឃឹមចំពោះគីឌានទេ គឺទេវតានិយាយដល់គាត់ថា «ដោយសារកម្លាំងដែលអ្នកមាន ចូរទៅសង្គ្រោះអ៊ីស្រាអែលអោយរួចពីកណ្តាប់ដៃរបស់ជនជាតិម៉ាឌាន គឺយើងចាត់អ្នកអោយទៅ!»។ (៦:១៤)

យើងបានគិតថា គីឌានគួរតែមានចិត្តចង់ធ្វើតាមព្រះហឫទ័យរបស់ព្រះ ហើយរកសេរីភាពសំរាប់ប្រជាជនផងព្រះ ប៉ុន្តែគាត់ព្យាយាមរកមូលហេតុ ដើម្បីរត់ចេញពីព្រះបន្ទូលនេះទៅវិញ បានជាគាត់បានឆ្លើយប្រាប់ថា

«លោកម្ចាស់អើយ ធ្វើដូចម្តេចអោយខ្ញុំប្របាទអាចសង្គ្រោះអ៊ីស្រាអែលបាន? ដ្បិតក្នុងកុលសម្ព័ន្ធម៉ាណាសេ អំបូររបស់ខ្ញុំប្របាទខ្សត់ខ្សោយជាងគេ ហើយក្នុងគ្រួសាររបស់ខ្ញុំប្របាទទៀតសោត ក៏ខ្ញុំប្របាទក្មេងជាងគេដែរ»។ (៦:១៥)

នៅពេលគីឌានមើលមកខ្លួនឯងថា គាត់ជាមនុស្សខ្សោយ ព្រះត្រូវជួយគាត់ ដោយទ្រង់មានបន្ទូលថា

«យើងនឹងស្ថិតនៅជាមួយអ្នក ហើយអ្នកនឹងវាយឈ្នះជនជាតិម៉ាឌាន ដូចវាយជាមួយនឹងមនុស្សតែម្នាក់»។ (៦:១៦)

ព្រះបន្ទូលនេះស្រដៀងគ្នានឹងព្រះបន្ទូលទៅកាន់អ្នកដឹកនាំអស្ចារ្យម្នាក់ដែរគឺ យ៉ូស្វេ ដែលថា

(យ៉ូស្វេ ១:៥) ‹‹យើងស្ថិតនៅជាមួយអ្នក ដូចយើងធ្លាប់ស្ថិតនៅជាមួយម៉ូសេដែរ។ យើងនឹងជួយអ្នកជានិច្ច យើងមិនបោះបង់ចោលអ្នកឡើយ។››

ប៉ុន្តែគីឌាននៅតែមិនសប្បាយចិត្តសោះ គឺគាត់នៅតែត្រូវការទំនុកចិត្តបន្ថែមទៀត

(៦:១៧) «ប្រសិនបើលោកគាប់ចិត្តខ្ញុំប្របាទមែន សូមផ្ដល់ទីសំគាល់មួយអោយខ្ញុំប្របាទបានដឹងថា លោកពិតជា**ព្រះអម្ចាស់**ដែលកំពុងតែមានព្រះបន្ទូលមកខ្ញុំប្របាទមែន! »

គីឌានបានទៅរៀបចំតង្វាយស្អុគស្អាញ នៅពេលដែលភ្ញៀវរបស់គាត់ត្រូវរង់ចាំ ហើយទេវតារបស់ព្រះជាម្ចាស់បានចង់ចាំដោយអត់ធ្មត់។ បើយើងស្រាវជ្រាវប្រភេទនៃតង្វាយរបស់គីឌាន យើងបានឃើញថា គួរអោយសោកស្ដាយចំពោះស្ថានភាពខាងវិញ្ញាណរបស់ពួកអ៊ីស្រាអែល ពីព្រោះគីឌានបានរៀបចំតង្វាយនេះ គឺដើម្បីប្រទានម្ហូបដល់ព្រះ គឺគាត់មិនរៀបចំថ្វាយបង្គំព្រះយ៉ាវេតាមក្រឹត្យវិន័យ ដែលពួកគេបានទទួលតាមរយៈលោកម៉ូសេឡើយ។

បងប្អូន យើងងាយស្រួលនឹងធ្លាក់ទៅក្នុងគំនិតខុសថា យើងអាចប្រើព្រះ ឬគ្រប់គ្រងព្រះតាមរយៈតង្វាយរបស់យើង មិនមែនទេ គឺយើងត្រូវប្រែចិត្ត និងព្យាយាមរកមេត្តាករុណារបស់ទ្រង់វិញ។ យើងគិតថាការស្ដាប់បង្គាប់តាមសាសនាគឺជាការបំរើស្របតាមព្រះហឫទ័យទ្រង់ ប៉ុន្តែយើងត្រូវទុកចិត្តលើព្រះរាជកិច្ចរបស់ទ្រង់ ដែលទ្រង់បានធ្វើសំរាប់យើងហើយ។

ទោះបីគីឌានមិនដឹង មិនយល់អំពីរបៀប ដែលគាត់គួរធ្វើតាមព្រះហឫទ័យព្រះក៏ដោយ ក៏ទេវតារបស់ព្រះបាននិយាយថា

«ចូរដាក់សាច់ និងនំបុ័ងឥតមេលើថ្មនេះទៅ រួចចាក់ទឹកសម្លពីលើផង»។ ទេវតារបស់**ព្រះអម្ចាស់**យកចុងដំបងដែលលោកកាន់ទៅពាល់សាច់ និងនំបុ័ងឥតមេ ពេលនោះ មានភ្លើងផុសចេញពីថ្ម ហើយឆេះសាច់ និងនំបុ័ងអស់ទៅ។ បន្ទាប់មក ទេវតារបស់**ព្រះអម្ចាស់**ក៏កំបាំងបាត់ទៅ។ (៦:២០-២១)

ឥឡូវនេះ គីឌានបានដឹងយ៉ាងច្បាស់ហើយថា នេះជាទេវតារបស់ព្រះជាម្ចាស់។ ពិតប្រាកដ

ណាស់ គាត់បែកញើស និងវិលមុខ ពីព្រោគាត់ជាមនុស្សខ្លាច ហើយការមិនជឿរបស់គាត់ បានធ្វើអោយគាត់បានចោតសួរទេវតារបស់ព្រះ។ ប្រហែលជាគាត់បានគិតពីស្ថានភាពនៅក្នុងប្រវត្តិសាស្ត្រសាស្ត្ររបស់អ៊ីស្រាអែល គឺនៅពេលដែលព្រះពេញដោយព្រះពិរោធ នោះនឹងមានមនុស្សជាច្រើនបានស្លាប់ ហើយសកម្មភាពនេះព្រះចង់បង្ហាញអំពីភាពបរិសុទ្ធរបស់ទ្រង់។ប៉ុន្តែ...

**ខ.២៣ ព្រះអម្ចាស់**មានព្រះបន្ទូលមកលោកថា៖ «សុំអោយអ្នកបានប្រកបដោយសេចក្តីសុខសាន្ត កុំខ្លាចអ្វីឡើយ អ្នកនឹងមិនស្លាប់ទេ»។

**ព្រះអម្ចាស់**ចង់អោយមនុស្សមានចិត្តខ្លាចនេះ ក្លាយជាទៅអ្នកដឹកនាំរាស្ត្រផងទ្រង់។ តើគីឌានអាចទទួលការគោរពរបស់ពួកអ៊ីស្រាអែលដោយរបៀបណា?
ដូច្នោះទ្រង់បានបញ្ជាដល់គីឌានថា ទៅយកសត្វគោមួយក្បាល ‹‹ចូររំលំអាសនៈព្រះបាលរបស់ឪពុកអ្នក ព្រមទាំងកាប់បំផ្លាញបង្គោលរបស់ព្រះអាសេរ៉ានៅក្បែរនោះផង។›› (៦:២៥)
ហើយគាត់ត្រូវធ្វើអាសនាត្រឹមត្រូវថ្វាយព្រះអម្ចាស់នៅកន្លែងនោះ ដែលនឹងជំនួសរូបព្រះនោះ ហើយគាត់ត្រូវយកគោទីពីរនោះមកដុតទាំងមូលធ្វើជាយញ្ញបូជា ដោយយកបង្គោលព្រះអាសេរ៉ា ដែលអ្នកបានកាប់នោះ មកធ្វើជាអុសសំរាប់ដុត»

តែគីឌានខ្លាចណាស់ គឺគាត់ខ្លាចគ្រួសាររបស់គាត់ គាត់ខ្លាចមនុស្សប្រុសៗនៅក្នុងភូមិ ដូច្នេះហើយបានជាគាត់បានធ្វើកិច្ចការទាំងនេះនៅពេលយប់ងងឹត ជាពេលដែលពួកគេកេងលក់ស្រួលហើយមិនអាចឃើញកិច្ចការគាត់បាន ។ ប្រហែលជាគីឌានជាមនុស្សស្តាប់បង្គាប់ ប៉ុន្តែគាត់មិនជាវីរបុរសទេ។

នៅពេលមនុស្សនៅក្នុងភូមិបានរកឃើញ ការប្រមាថដែលបានកើតឡើង ពួកគេមកដើម្បីរកអ្នកណា ដែលបានបំផ្លាញរូបព្រះរបស់ពួកគេ ដូច្នេះគេបានមកដល់ផ្ទះរបស់ឪពុកគីឌាន គឺលោកយ៉ូអាស។

លោកយ៉ូអាសបានបាត់សត្វគោមួយក្បាល ដែលមានតម្លៃ ហើយនៅពេលនោះប្រហែលជា

គាត់មានអារម្មណ៍ដូចជាឪពុកម្នាក់ ដែលកូនប្រុសរបស់ខ្លួនបានលក់ឡាន ឡិចស៊ីស Lexus របស់គ្រួសារ ហើយបានបំផ្លាញទីធ្សក្ការបូជារបស់គ្រួសារដែរ។ ដូច្នេះយើងគួរគិតថា លោកយ៉ូអាសខឹងគីឌានខ្លាំងណាស់នៅពេលនោះ។ ប៉ុន្តែដូចជាយើងឃើញថា គាត់បានប្រែចិត្ត ពីព្រោះគាត់បាននិយាយដល់មនុស្សភូមិថា

«បើព្រះបាលពិតជាព្រះមែន ទុកអោយលោកតវ៉ាខ្លួនឯងផ្ទាល់ទៅ ព្រោះគេបានរំលំអាសនៈរបស់លោក!» (៦:៣១)

លើសពីនេះ ហ្វូងមនុស្សក៏បានស្ងប់ចិត្ត។

ការសន្និដ្ឋានលើភាពប្រឆាំងនេះសំខាន់ ៖

ខ.៣២ ចាប់តាំងពីពេលនោះមក អ្នកភូមិហៅលោកគេឌានថា «យេរូបាល» ដោយពោលថា «សូមអោយព្រះបាលតវ៉ានឹងគាត់ទៅ ដ្បិតគាត់បានរំលំអាសនៈរបស់លោក»។

ឈ្មោះថ្មីនេះ បានបង្ហាញជាសាធារណៈថា គីឌានជាមនុស្សដែលបានឈ្នះលើព្រះបាល គឺគាត់ជាភស្តុតាងនៃភាពខូចនៃព្រះបាល។

អញ្ចឹងហើយបានជានៅពេលពួកម៉ាឌានបានប្រមូលគ្នាជាមួយប្រជាជាតិដទៃទៀត ដើម្បីទៅបំផ្លាញពួកអ៊ីស្រាអែល នោះគីឌានអាចប្រមូលគ្នាបានបួនកុលសម្ព័ន្ធនៃពួកអ៊ីស្រាអែល ដើម្បីការពារពួកគេចេញពីការកំរាមកំហែងនេះ។ សូមកាត់សំគាល់ខ ៣៤-៣៥

ខ.៣៤ ព្រះវិញ្ញាណនៃ**ព្រះអម្ចាស់**យាងមកគង់ក្នុងលោកគេឌាន លោកក៏ផ្លុំស្នែង ដើម្បីកោះហៅប្រជាជនក្នុងអំបូរអបៀស៊ើរ អោយមកតាមលោក។ លោកចាត់អ្នកនាំសារអោយទៅដែនដីរបស់កុលសម្ព័ន្ធម៉ាណាសេទាំងមូល ដើម្បីកេណ្ឌមនុស្សមកតាមលោក។ លោកបានចាត់អ្នកនាំសារអោយទៅដែនដីរបស់កុលសម្ព័ន្ធអេស៊ើរ សាប់យូឡូន និងណែបថាលីដែរ ហើយពួកគេក៏នាំគ្នាមករកលោក។

បើសិនយើងបានទទួលពាក្យបែបនេះ យើងបានយល់ថា ការសង្គ្រោះសំរាប់ពួកអ៊ីស្រាអែលនឹងកើតមានឡើង ដូចពេលដែលលោកអេហ៊ូដបានផ្លុំស្នែង ដើម្បីពួកអ៊ីស្រាអែលអាចឈ្នះលើជនជាតិម៉ូអាប់ដែរ ប៉ុន្តែគីឌានមានភាពស្ទាក់ស្ទើរ គឺគាត់មិនជឿ ហើយគាតចង់បានទីសំគាល់មួយទៀតពីព្រះ។

ដូច្នេះ គីឌាននិយាយដល់ព្រះថា

«ព្រះអង្គមានព្រះបន្ទូលថា ទ្រង់នឹងសង្គ្រោះអ៊ីស្រាអែល តាមរយៈទូលបង្គំ ដូច្នេះ ទូលបង្គំសូមលាតស្បែកចៀមនៅលើលានបោកស្រូវ។ ប្រសិនបើទឹកសន្សើមធ្លាក់តែលើស្បែកចៀម ហើយដីនៅជុំវិញស្ងួត នោះទូលបង្គំនឹងដឹងថា ព្រះអង្គពិតជាសព្វព្រះហឫទ័យសង្គ្រោះអ៊ីស្រាអែល តាមរយៈទូលបង្គំ ដូចព្រះអង្គមានព្រះបន្ទូលមែន»។ (៦:៣៦-៣៧)

ស្បែកចៀម ឬរោមចៀម មានគុណសម្បត្តិក្នុងការស្រូបយកទឹក ដូច្នេះហើយបាននៅស្រុកអូស្ត្រាលី យើងប្រើស្រោមជើង ដែលធ្វើពីរោមចៀម ដើម្បីអោយយើងអាចមានជើងស្ងួត។

នៅពេលគីឌានឃើញថា ទីសំគាល់នេះបានកើតឡើង គាត់គិតថា ទីសំគាល់នេះស្រួលណាស់ ដូច្នេះឥឡូវនេះគាត់បានសុំអោតរោមចៀមស្ងួតហើយសន្សើមធ្លាក់ជោកដីវិញ ដែលការនេះខុសពីរបៀបធម្មជាតិហើយ។

ខ.៤០ យប់នោះ ព្រះជាម្ចាស់បានធ្វើតាមសំណូមពររបស់លោកគេឌាន គឺមានតែស្បែកចៀមទេដែលស្ងួត ហើយដីទាំងអស់ដែលនៅជុំវិញ ជោកទៅដោយទឹកសន្សើម។

<u>**តួនាទីរបស់ព្រះ**</u>

បងប្អូន នៅក្នុងរឿងនេះ យើងអាចឃើញម្តងទៀតថា ព្រះអម្ចាស់មានព្រះគុណចំពោះរាស្ត្ររបស់ទ្រង់។ ពួកអ៊ីស្រាអែលបន្តថ្វាយបង្គំរូបព្រះ ទោះបើព្រះបានចាត់ព្យាការីរបស់ទ្រង់ ដើម្បី**ដាស់តឿន**ពួកគេ ហើយទោះបើទ្រង់បានយកសត្រូវនិងសេចក្តីវេទនារបស់ពួកគេចេញសំរាប់ពេលវេលាយូរក៏ដោយ។

យើងអាចឃើញ**ព្រះគុណ**របស់ព្រះ តាមរយៈការត្រាស់ហៅអ្នកសង្គ្រោះសំរាប់រាស្ត្រទ្រង់ គឺលោកគីឌាន គឺគាត់នឹងឈ្នះជនជាតិម៉ាឌាន និងក្រោយមកពួកអ៊ីស្រាអែលនិងទទួលបាន

សន្តិភាពអស់រយៈពេល៤០ឆ្នាំ។

តើយើងគួរតែសួរថា ហេតុអ្វីព្រះបានត្រាស់ហៅគីឌាន?

គីឌានជាបុរសមានចិត្តខ្លាចសត្រូវ គ្មានជំនឿលើព្រះ ហើយព្រះត្រូវធ្វើទីសំគាល់ជាច្រើន ដើម្បីអោយគីឌានអាចទុកចិត្តលើទ្រង់បាន។

ប៉ុន្តែព្រះបានប្រើមនុស្សមានចិត្តខ្លាច ដែលមិនជឿ ដើម្បីបង្ហាញព្រះគុណរបស់ទ្រង់ចំពោះពួកអ៊ីស្រាអែល ហើយបានសង្គ្រោះពួកគេចេញពីអំណាចរបស់ជនជាតិម៉ាឌាន។

__ការអនុវត្ត__

បងប្អូន ព្រះអាចធ្វើអោយមនុស្សមានចិត្តខ្លាចនិងមិនជឿបានក្លាយជាអ្នកដឹកនាំ ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ចេញពីអំណាចរបស់ពួកខ្លាំងសត្រូវនៅក្នុងសម័យពួកចៅហ្វាយ។ មួយពាន់ឆ្នាំក្រោយមក ព្រះបានចាត់អ្នកសង្គ្រោះមួយទៀត តែឥឡូវនេះទ្រង់បានចាត់ព្រះរាជបុត្រារបស់ទ្រង់ម្តង គឺព្រះយេស៊ូវគ្រីស្ទ។

ព្រះយេស៊ូវបានធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតា រហូតដល់ទ្រង់បានសុគតនៅលើឈើឆ្កាង ដើម្បីអោយសត្រូវរបស់រាស្ត្ររបស់ព្រះ គឺអំណាចបាបនិងសេចក្តីស្លាប់ ត្រូវចុះចាញ់ជារៀងរហូត។

ដូច្នេះ ទោះបីយើងអាចជាមនុស្សខ្លាច មនុស្សខ្សោយ ឬមនុស្សឥតមានជំនឿខ្លាំង យើងនៅតែអាចទុកចិត្តលើទ្រង់សំរាប់សេចក្តីសង្គ្រោះចេញពីអំណាចរបស់បាបនិងសេចក្តីស្លាប់បានដែរ។

តែនៅក្នុងចំណោមយើង មានមនុស្សខ្លះដែលមានការទទួលខុសត្រូវ ប្រហែលជាចំពោះគ្រួសារ ឬចំពោះអង្គការ ឬចំពោះក្រុមជំនុំ។

- តយើងបានរកការណែនាំដោយរបៀបណា?
- តើអ្នកព្យាយាមរកព្រះហឫទ័យរបស់ព្រះដោយរបៀបណា?
- តើព្រះចង់អោយយើងធ្វើអ្វីនៅក្នុងជីវិត?

ប្រហែលជានៅក្នុងចំណោមយើង មានមនុស្សខ្លះដូចលោកគីឌានដែរ គឺជាអ្នកគ្មានជំនឿ គឺជាអ្នកចង់រកទីសំគាល់ចេញពីព្រះ មុននឹងធ្វើកិច្ចការអ្វីមួយ។

បងប្អូន សូមចាំថា

- ព្រះមានព្រះរាជកិច្ចអស្ចារ្យ គឺទ្រង់បានត្រាស់ហៅមនុស្សម្នាក់មានចិត្តខ្លាចដូចជាលោកគីឌាន ហើយទ្រង់បានប្រើគាត់ ដើម្បីដឹកនាំប្រជារាស្ត្ររបស់ទ្រង់ និងឈ្នះលើសត្រូវរបស់ពួកគេ ហើយទ្រង់បានការពារមនុស្សនៅក្នុងសម្ព័ន្ធមេត្រីរបស់ទ្រង់។ ទ្រង់អាចធ្វើទីអស្ចារ្យក្នុងរបៀបជាច្រើន ហើយទ្រង់បានធ្វើអន្តរាគមន៍ជាច្រើន។

- បើយើងចង់រកការដឹកនាំ យើងត្រូវរកនៅក្នុងព្រះបន្ទូលនៅក្នុង ២ ធីម៉ូថេ ៣:១៦

‹‹គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង និងមានប្រយោជន៍សំរាប់បង្រៀន រកខុសត្រូវ កែតម្រង់ និងអប់រំអោយរស់តាមសេចក្ដីសុចរិត...››

- ដូច្នេះសូមប្រយ័ត្ន ចូរកុំចង់បានទីសំគាល់ឡើយ ពីព្រោះយើងបានទទួលទីសំគាល់អស្ចារ្យនិងសំខាន់ជាងរួចទៅហើយ គឺទីសំគាល់ដែលលោកគីឌានបានឃើញ។
- នៅក្នុងរឿងប្រៀបប្រដូចរបស់ព្រះយេស៊ូវ អំពីបុរសអ្នកមាននិងលោក ឡាសារ យើងឃើញការព្រមានអំពីកន្លែងនៃទារុណកម្មសំរាប់អស់អ្នកណាដែលមិនជឿ។ បុរសអ្នកមានបានអង្វរដល់លោកអ័ប្រាហាំថា
- «លោកឪពុកអើយ! សូមលោកឪពុកមេត្តាចាត់ឡាសារអោយទៅផ្ទះឪពុកខ្ញុំផង ខ្ញុំមានបងប្អូនប្រាំនាក់។ សូមអោយឡាសារទៅប្រាប់គេអោយដឹងខ្លួន កុំអោយគេមកកន្លែងរងទុក្ខទារុណកម្មនេះ»។
- លោកអប្រាហាំឆ្លើយថា «បងប្អូនរបស់កូនបានឮពាក្យប្រៀនប្រដៅរបស់លោកម៉ូសេ និងពាក្យប្រៀនប្រដៅរបស់ពួកព្យាការីហើយ អោយគេធ្វើតាមពាក្យលោកទាំងនោះចុះ»។
- អ្នកមានតបទៅលោកអប្រាហាំថា «ទេ! លោកឪពុក ទាល់តែមានអ្នកណាម្នាក់ ពីចំណោមមនុស្សស្លាប់ទៅប្រាប់គេ ទើបគេកែប្រែចិត្តគំនិត»។

- ប៉ុន្តែ លោកអប្រាហាំឆ្លើយតបវិញថា «ប្រសិនបើគេមិនធ្វើតាមពាក្យប្រៀនប្រដៅរបស់លោកម៉ូសេ និងពាក្យប្រៀនប្រដៅរបស់ព្យាការីទេ ទោះបីមានមនុស្សស្លាប់បានរស់ឡើងវិញ ទៅប្រាប់គេក៏ដោយ ក៏គេមិនព្រមជឿដែរ»។ (លូកា ១៦:២៧-៣១)

បងប្អូន តើអ្នកចង់ទទួលបានទីសំគាល់ប្រភេទណា? ព្រះយេស៊ូវជាអង្គសង្គ្រោះ ដែលបានយាងមកក្នុងលោកីយ៍នេះ គឺទ្រង់បានសុគត រស់ឡើងវិញ និងត្រូវបានលើកឡើងទៅស្ថានសួគ៌ ហើយឥឡូវនេះទ្រង់សោយរាជ្យជាមួយព្រះវរបិតារបស់ទ្រង់។ ហេតុអ្វីយើងត្រូវការទីសំគាល់ដទៃទៀត ដើម្បីទុកចិត្តលើទ្រង់ដូច្នេះ?
យើងត្រូវទុកចិត្ត និងជឿលើអ្វីៗដែលត្រឹមត្រូវ គឺយើងត្រូវទុកចិត្តលើតែដំណឹងល្អរបស់ព្រះយេស៊ូវប៉ុណ្ណោះ។
រ៉ូម ១០:១៧ បានសរសេរថា ‹‹ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ រីឯសេចក្តីដែលយើងបានស្តាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រីស្ទ។››

- 

**សូមអធិស្ឋាន**

ឱព្រះជាម្ចាស់ដ៏មានអំណាចគ្រប់ព្រះចេស្តាអើយ!
ព្រះបុត្រារបស់ព្រះអង្គបានបើកសម្តែងនៅក្នុងទីសម្គាល់និងការអស្ចារ្យ
ដែលជាឫទ្ធិបាដិហារិយ៍នៃសេចក្តីស្រឡាញ់ដ៏ជួយសង្គ្រោះរបស់ព្រះអង្គ
សូមធ្វើជាថ្មីដោយព្រះគុណដែលទ្រង់បានបង្ហាញដល់ពួកអ៊ីស្រាអែល តាមរយៈលោកគីឌាន នៅក្នុងគ្រប់ទាំងសេចក្តីកម្សោយរបស់គាត់
នោះសូមព្រះអង្គជួយគាំទ្រយើងខ្ញុំ ដោយឫទ្ធានុភាពដ៏មានអំណាចគ្រប់ព្រះចេស្តតាមរយៈព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះអម្ចាស់របស់យើងខ្ញុំ។ អាម៉ែន